Disability Rights California
ប្រព័ន្ធការពារ និងការតស៊ូមតិ រដ្ឋកាលីហ្វ័រនីញ៉ា

# បទដ្ឋានរយៈពេលធ្វើដំណើរទៅកាន់ និងចម្ងាយនៃទីកន្លែងរបស់អ្នកផ្តល់សេវាកម្ម ផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែងជាមុន (Medi-Cal Managed Care)

*ខែឧសភា ឆ្នាំ2018 ឯកសារបោះពុម្ពផ្សាយ #5610.06*

## បទដ្ឋានរយៈពេលធ្វើដំណើរទៅកាន់ និងចម្ងាយនៃទីកន្លែងរបស់អ្នកផ្តល់សេវាកម្ម ផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែងជាមុន (Medi-Cal Managed Care)

ដើម្បីធានាបានថា សេវាកម្មមានផ្តល់ជូន ហើយអ្នកទទួលផលអាចទទួលបានសេវាកម្មទាំងអស់នោះ ដោយមិនបាច់ចំណាយពេលច្រើន ផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែងជាមុន[1] ត្រូវរក្សាឲ្យបាននូវបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានទីតាំង ឬក្នុងរយៈពេល ឬរយៈចម្ងាយដែលបានកំណត់ ពីទីកន្លែងស្នាក់នៅរបស់អតិថិជន ។[2] នៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មាននិយាយអំពីបទដ្ឋាននៃពេលវេលា និងចម្ងាយ របស់អ្នកផ្តល់

---

[1] សម្រាប់ព័ត៌មានបន្ថែមអំពីផែនការថែទាំសុខភាពដែលមានការចាត់ចែងជាមុន សូមអានឯកសារបោះពុម្ពរបស់យើងខ្ញុំ ស្តីអំពី ផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែងជាមុន (Medi-Cal Managed Care Health Plans) ៖ តើទាំងនោះជាអ្វី? តើខ្ញុំត្រូវដឹងអ្វីខ្លះអំពីរបស់ទាំងនោះ? "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[2] សូមអាន ក្រមសុខុមាលភាព និងវិទ្យាស្ថានកាលីហ្វ័នីញ៉ា (California Welfare & Institutions Code) ផ្នែកទី §14197 ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

សេវាកម្មតាមប្រភេទនៃ ។[3]

1. **តើពេលវេលា និងចម្ងាយផ្លូវជាបទដ្ឋានសម្រាប់ធ្វើដំណើរទៅកាន់ទីតាំងរបស់អ្នកផ្តល់សេវាកម្មថែទាំវេជ្ជសាស្ត្រ មានចំនួនប៉ុន្មាន?**

សម្រាប់ការថែទាំសុខភាពជាបទដ្ឋាន គឺយើងប្រើបទដ្ឋានដូចខាងក្រោម ចាប់ពីថ្ងៃទី 1 ខែមករា 2018[4] ៖

អ្នកផ្តល់សេវាកម្មថែទាំបឋម (ពេទ្យកុមារ និងពេទ្យមនុស្សធំ) ត្រូវមានទីតាំងរវាង **ដប់ (10) ម៉ាយល៍ ឬសាមសិប (30) នាទី** ពីផ្ទះរបស់អ្នក ។

មន្ទីរពេទ្យត្រូវមានទីតាំងក្នុងរវាង **ដប់ប្រាំ (15) ម៉ាយល៍ ឬសាមសិប (30) នាទី** ពីផ្ទះរបស់អ្នក ។

សេវាកម្មថែទាំសុខភាពធ្មេញ ដែលស្ថិតក្រោមផែនការជានារ៉ាប់រងរបស់ Medi-Cal ដែលមានការចាត់ចែងទុកជាមុន ត្រូវមានទីតាំងក្នុងរវាង **ដប់ (10) ម៉ាយល៍ ឬសាមសិប (30) នាទីពី** ផ្ទះរបស់អ្នក ។[5]

---

[3] សម្រាប់ព័ត៌មានបន្ថែម អំពីបទដ្ឋានការណាត់ជួប សម្រាប់សេវាកម្មណាមួយ សូមអានឯកសារបោះពុម្ពផ្សាយរបស់យើងខ្ញុំ ស្តីអំពី *ការទទួលបានសេវាកម្មទាន់ពេលវេលាលើការថែទាំសុខភាព (Timely Access to Medical Care)* "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[4] 14197(c) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[5] សម្រាប់ព័ត៌មានបន្ថែម សូមអានឯកសារស្តីអំពី ផែនការចាត់ចែងជាមុនទាំងអស់របស់ Medi-Cal លើការថែទាំសុខភាពធ្មេញ (All Medi-Cal Dental Managed Care Plans) ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

អ្នកផ្តល់ការថែទាំបឋមខាងសម្ភព និងរោគស្ត្រី *ត្រូវមានទីតាំងក្នុងរវាង* **ដប់ (10) ម៉ាយល៍ ឬសាមសិប (30) នាទី** ពីផ្ទះរបស់អ្នក ។

2. **តើពេលវេលា និងចម្ងាយផ្លូវជាបទដ្ឋានសម្រាប់ធ្វើដំណើរទៅកាន់ទីតាំងរបស់អ្នកផ្តល់សេវាកម្មថែទាំវេជ្ជសាស្ត្រឯកទេស មានចំនួនប៉ុន្មាន?**

គិតមកត្រឹមថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2018 ផែនការថែទាំសុខភាព Medi-Cal ដែល

មានការចាត់ចែងជាមុន ត្រូវរក្សាឲ្យបាននូវបណ្តាញអ្នកផ្តល់សេវាកម្ម ឯកទេស[6] (ពេទ្យកុមារ និងពេទ្យមនុស្សចាស់) ជាមួយបទដ្ឋាន ទៅតាមខោនធីដែលអ្នករស់នៅ ។[7] បើអ្នករស់នៅក្នុង ៖

> ខោនធី Alameda, Contra Costa, Los Angeles, Orange, Sacramento, San Diego, San Francisco, San Mateo ឬខោនធី Santa Clara ៖ Medi-Cal នឹងរក្សាទុកនូវបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានទីតាំងរហូតដល់ **ដប់ប្រាំ (15) ម៉ាយល៍ ឬសាមសិប (30) នាទី** ពីផ្ទះរបស់អ្នក ។
>
> ខោនធី Marin, Placer, Riverside, San Joaquin, Santa Cruz, Solano, Sonoma, Stanislaus ឬខោនធី Ventura ៖ Medi-Cal នឹងរក្សាទុកនូវបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានទីតាំងរហូតដល់ **សាមសិបម៉ាយល៍ (30) ឬហុកសិប (60) នាទី** ពីផ្ទះរបស់អ្នក ។

---

[6] "ពេទ្យឯកទេស-Specialist" មានន័យថា ពេទ្យដែលមានជំនាញវិជ្ជាជីវៈតាមផ្នែកខាងក្រោម ៖ ការសិក្សាពីបេះដូង/ការព្យាបាលដោយការដោយទុយ៉ូចូលក្នុងបេះដូង ការសិក្សាពីតំរងនោម ការសិក្សាពីរោគសើរស្បែក ការសិក្សាខាងសរសៃប្រសាទ ការសិក្សាពីក្រពេញបញ្ចេញក្នុង ចក្ខុរោគសាស្ត្រ ត្រចៀក ច្រមុះ និងបំពង់ក/ការសិក្សាពីជំងឺត្រចៀកនិងបំពង់ក ការវះកាត់សាច់ដុំ និងឆ្អឹង ការសិក្សាពីក្រពះ វេជ្ជសាស្ត្ររូបវន្ត និងការស្តារនីតិសម្បទា ការវះកាត់ទូទៅ ពេទ្យខាងវិកលចរិក ការសិក្សាអំពីឈាម សាច់ពក ការសិក្សាអំពីសួត មេរោគអេដស៍/ជំងឺអេដស៍/ជំងឺឆ្លងនានា ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[7] WIC 14197(c) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

ខោនធី Amador, Butte, El Dorado, Fresno, Kern, Kings, Lake, Madera, Merced, Monterey, Napa, Nevada, San Bernardino, San Luis Obispo, Santa Barbara, Sutter, Tulare, Yolo ឬខោនធី Yuba ៖ Medi-Cal នឹងរក្សាទុកនូវបណ្ដាញអ្នកផ្ដល់សេវាកម្មដែលមានចម្ងាយរហូតដល់ **សែសិបប្រាំ (45) ម៉ាយល៍ ឬចិតសិបប្រាំ (75) នាទី** ពីផ្ទះរបស់អ្នក ។

ខោនធី Alpine, Calaveras, Colusa, Del Norte, Glenn, Humboldt, Imperial, Inyo, Lassen, Mariposa, Mendocino, Modoc, Mono, Plumas, San Benito, Shasta, Sierra, Siskiyou, Tehama, Trinity, ឬខោនធី Tuolumne ៖ Medi-Cal នឹងរក្សាទុកបណ្ដាញអ្នកផ្ដល់សេវាកម្មដែលមានចម្ងាយរហូតដល់ **ហុកសិបម៉ាយល៍ (60) ឬកៅសិប (90) នាទី** ពីផ្ទះរបស់អ្នក ។

បទដ្ឋានទាំងអស់នេះ ក៏មានការលើកលែងដែរ ៖ នៅពេលដែល ពេទ្យឯកទេសមានទីតាំងបឋមនៅក្នុងមន្ទីរពេទ្យណាមួយ ឬនៅក្នុងគ្លីនិកជាលក្ខណៈមន្ទីរពេទ្យ ឬពេលដែលគ្លីនិកមិនត្រូវការជួបមុខផ្ទាល់ជាមួយអ្នកជំងឺ ដើម្បីផ្ដល់សេវាកម្ម (ដូចជាផ្នែករោគសាស្ត្រ ឬផ្នែករូបភាពវេជ្ជសាស្ត្រ ឬផ្នែកវិទ្យុសាស្ត្រ) គឺបទដ្ឋានពេលវេលា និងចម្ងាយមិនបាច់យកមកប្រើឡើយ ។[8]

លើសពីនេះ ពេទ្យឯកទេសពិសេសៗមួយចំនួន ត្រូវបានដកឈ្មោះចេញពីបញ្ជីនេះដោយចេតនា ដោយសារថា ប្រភេទនៃបទដ្ឋានទាំងអស់នេះ មិនមានភាពសមរម្យចំពោះពួកគេឡើយ ។[9]

---

[8] នាយកដ្ឋានសេវាកម្មថែទាំសុខភាពកាលីហ្វ័រនីញ៉ា (CA Dept. of Health Care Services) *បទបញ្ញត្តិចុងក្រោយអំពីការថែទាំសុខភាព Medicaid ដែលមានការចាត់ចែងជាមុន (Medicaid Managed Care Final Rule) ៖ បទដ្ឋានភាពគ្រប់គ្រាន់ក្នុងបណ្ដាញ (Network Adequacy Standards)* ទំព័រ 15 (2017). “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

[9] Id. “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

### 3. តើពេលវេលា និងចម្ងាយផ្លូវជាបទដ្ឋានសម្រាប់ធ្វើដំណើរទៅកាន់ទីតាំងឱសថស្ថាន មានចំនួនប៉ុន្មាន?

គិតមកត្រឹមថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2018 សម្រាប់ សេវាកម្មឱសថស្ថាន ផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែងជាមុន ត្រូវរក្សាទុកបណ្ដាញអ្នកផ្ដល់សេវាកម្ម ដែលមានចម្ងាយរហូតដល់ **ដប់ (10) ម៉ាយល៍ ឬសាមសិប (30) នាទី** ពីផ្ទះរបស់អ្នក ។[10]

### 4. តើពេលវេលា និងចម្ងាយផ្លូវជាបទដ្ឋានសម្រាប់ធ្វើដំណើរទៅកាន់ទីតាំងរបស់អ្នកផ្ដល់សេវាកម្មថែទាំសុខភាពផ្លូវចិត្តមិនសម្រាកពេទ្យ មានចំនួនប៉ុន្មាន?

គិតមកត្រឹមថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2018 ផែនការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែងជាមុន ត្រូវរក្សាទុកបណ្ដាញអ្នកផ្ដល់សេវាកម្មថែទាំសុខភាពផ្លូវចិត្តរបស់អ្នកជំងឺមិនសម្រាកពេទ្យ សម្រាប់អ្នកទទួលសេវាកម្មនេះ ។[11] បើអ្នករស់នៅក្នុង ៖

ខោនធី Alameda, Contra Costa, Los Angeles, Orange, Sacramento, San Diego, San Francisco, San Mateo ឬខោនធី Santa Clara ៖ Medi-Cal នឹងរក្សាទុកនូវបណ្ដាញអ្នកផ្ដល់សេវាកម្ម ដែលមានទីតាំងរហូតដល់ **ដប់ប្រាំ (15) ម៉ាយល៍ ឬសាមសិប (30) នាទី** ពីផ្ទះរបស់អ្នក ។

ខោនធី Marin, Placer, Riverside, San Joaquin, Santa Cruz, Solano, Sonoma, Stanislaus ឬខោនធី Ventura ៖ Medi-Cal នឹងរក្សាទុកនូវបណ្ដាញអ្នកផ្ដល់សេវាកម្ម ដែលមានទីតាំងរហូតដល់ **សាមសិបម៉ាយល៍ (30) ឬហុកសិប (60) នាទី** ពីផ្ទះរបស់អ្នក ។

ខោនធី Amador, Butte, El Dorado, Fresno, Kern, Kings, Lake, Madera, Merced, Monterey, Napa, Nevada, San Bernardino, San Luis Obispo, Santa Barbara, Sutter, Tulare, Yolo ឬខោនធី Yuba ៖Medi-Cal នឹងរក្សា

---

[10] WIC §14197(c)(2) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[11] WIC §14197(c)(3) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

ទុកនូវបណ្តាញអ្នកផ្តល់សេវាកម្មដែលមានចម្ងាយរហូតដល់ **សែសិបប្រាំ (45) ម៉ាយល៍ ឬចិតសិបប្រាំ (75) នាទី** ពីផ្ទះរបស់អ្នក ។

ខោនធី Alpine, Calaveras, Colusa, Del Norte, Glenn, Humboldt, Imperial, Inyo, Lassen, Mariposa, Mendocino, Modoc, Mono, Plumas, San Benito, Shasta, Sierra, Siskiyou, Tehama, Trinity, ឬខោនធី Tuolumne ៖ Medi-Cal នឹងរក្សាទុកបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានចម្ងាយរហូតដល់ **ហុកសិបម៉ាលយ៍ (60) ឬកៅសិបនាទី (90)** ពីផ្ទះរបស់អ្នក ។

5. **តើពេលវេលា និងចម្ងាយផ្លូវជាបទដ្ឋានសម្រាប់ធ្វើដំណើរទៅកាន់ទីតាំងរបស់អ្នកផ្តល់សេវាកម្មព្យាបាលជំងឺញៀន និងកម្មវិធីព្យាបាលអ្នកប្រើថ្នាំញៀន (opioid) មានចំនួនប៉ុន្មាន?**

គិតមកត្រឹមថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2018 បទដ្ឋានសម្រាប់ពេលវេលា និងចម្ងាយធ្វើដំណើរទៅកាន់ទីកន្លែងអ្នកផ្តល់សេវាកម្មថែទាំអ្នកជំងឺញៀនថ្នាំមិនសម្រាកពេទ្យ (ក្រៅពីកម្មវិធីព្យាបាលអ្នកប្រើថ្នាំញៀន opioid) គឺអាស្រ័យលើខោនធីដែលអ្នករស់នៅផងដែរ[12] ៖

ខោនធី Alameda, Contra Costa, Los Angeles, Orange, Sacramento, San Diego, San Francisco, San Mateo និងខោនធី Santa Clara ៖ Medi-Cal នឹងរក្សាទុកនូវបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានទីតាំងរហូតដល់ **ដប់ប្រាំ (15) ម៉ាយល៍ ឬសាមសិប (30) នាទី** ពីផ្ទះរបស់អ្នក ។

ខោនធី Marin, Placer, Riverside, San Joaquin, Santa Cruz, Solano, Sonoma, Stanislaus និងខោនធី Ventura ៖Medi-Cal នឹងរក្សាទុកបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានចម្ងាយរហូតដល់ **សាមសិប (30) ម៉ាលយ៍ ឬហុកសិប (60) នាទី** ពីផ្ទះរបស់អ្នក ។

ខោនធី Alpine, Amador, Butte, Calaveras, Colusa, Del Norte, El Dorado, Fresno, Glenn, Humboldt, Imperial, Inyo, Kern, Kings, Lake,

---

[12] WIC §14197(c)(4)(A) “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

Lassen, Madera, Mariposa, Mendocino, Merced, Modoc, Monterey, Mono, Napa, Nevada, Plumas, San Benito, San Bernardino, San Luis Obispo, Santa Barbara, Shasta, Sierra, Siskiyou, Sutter, Tehama, Trinity, Tulare, Tuolumne, Yolo និងខោនធី Yuba ៖ Medi-Cal នឹងរក្សាទុកបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានចម្ងាយរហូតដល់ **ហុកសិប (60) ម៉ាយល៍ ឬកៅសិប (90) នាទី** ពីផ្ទះរបស់អ្នក ។

គិតមកត្រឹមថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2018 បទដ្ឋានពេលវេលា និងចម្ងាយផ្លូវធ្វើដំណើរមកកាន់កម្មវិធីព្យាបាលអ្នកប្រើគ្រឿងញៀនopioid ក៏អាស្រ័យលើខោនធីដែលអ្នករស់នៅផងដែរ[13] ៖

ខោនធី Alameda, Contra Costa, Los Angeles, Orange, Sacramento, San Diego, San Francisco, San Mateo និងខោនធី Santa Clara ៖Medi-Cal នឹងរក្សាទុកនូវបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានទីតាំងរហូតដល់ **ដប់ប្រាំ (15) ម៉ាយល៍ ឬសាមសិប (30) នាទី** ពីផ្ទះរបស់អ្នក ។

ខោនធី Marin, Placer, Riverside, San Joaquin, Santa Cruz, Solano, Sonoma, Stanislaus និងខោនធី Ventura ៖ Medi-Cal នឹងរក្សាទុកបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានចម្ងាយរហូតដល់ **សាមសិប (30) ម៉ាយល៍ ឬហុកសិប (60) នាទី** ពីផ្ទះរបស់អ្នក ។

ខោនធី Amador, Butte, El Dorado, Fresno, Kern, Kings, Lake, Madera, Merced, Monterey, Napa, Nevada, San Bernardino, San Luis Obispo, Santa Barbara, Sutter, Tulare, Yolo និងខោនធី Yuba ៖ Medi-Cal នឹងរក្សាទុកបណ្តាញអ្នកផ្តល់សេវាកម្ម ដែលមានចម្ងាយរហូតដល់ **សែសិបប្រាំ (45) ម៉ាលយ៍ ឬចិតសិបប្រាំ (75) នាទី** ពីផ្ទះរបស់អ្នក ។

ខោនធី Alpine, Calaveras, Colusa, Del Norte, Glenn, Humboldt, Imperial, Inyo, Lassen, Mariposa, Mendocino, Modoc, Mono, Plumas, San Benito, Shasta, Sierra, Siskiyou, Tehama, Trinity និងខោនធី Tuolumne ៖ Medi-Cal នឹងរក្សាទុកបណ្តាញអ្នកផ្តល់សេវាកម្ម ដែល

---

[13] WIC §14197(c)(4)(B) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

មានចម្ងាយរហូតដល់ **ហុកសិប (60) ម៉ាលយ៍ ឬកៅសិប (90) នាទី** ពីផ្ទះរបស់អ្នក ។

ប្រព័ន្ធផ្តល់ការថែទាំជំងឺញៀនថ្នាំ របស់ Medi-Cal ដែលមានការរៀបចំទុកជាមុន ត្រូវផ្តល់ការណាត់ជួប ក្នុងរវាងបីថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការព្យាបាលជំងឺញៀនថ្នាំញៀន opioid ។[14]

**6. តើពេលវេលា និងចម្ងាយផ្លូវជាបទដ្ឋានសម្រាប់ធ្វើដំណើរទៅកាន់ទីតាំងមណ្ឌលផ្តល់សេវាថែទាំព្យាបាល ឬមណ្ឌលផ្តល់សេវាថែទាំអន្តរការី មានចំនួនប៉ុន្មាន?**

ពេលវេលា និងចម្ងាយធ្វើដំណើរមកកាន់មណ្ឌលផ្តល់សេវាថែទាំព្យាបាលឯកទេស ឬមណ្ឌលផ្តល់សេវាថែទាំអន្តរការី ក៏អាស្រ័យលើទីតាំងរស់នៅរបស់អ្នកទទួលផលផងដែរ ៖

សម្រាប់អ្នករស់នៅក្នុងខោនធីAlameda, Contra Costa, Los Angeles, Orange, Sacramento, San Diego, San Francisco, San Mateo និងខោនធី Santa Clara ៖ ផែនការថែទាំសុខភាពដែលមានការរៀបចំទុកជាមុន ត្រូវផ្តល់សេវាកម្មនេះ ជូនអតិថិជនឲ្យបានក្នុងរវាង **ប្រាំ(5)** ថ្ងៃ នៃថ្ងៃធ្វើការ គិតពីពេលអ្នកបានស្នើសុំ ។[15]

សម្រាប់អ្នករស់នៅក្នុងខោនធី Marin, Placer, Riverside, San Joaquin, Santa Cruz, Solano, Sonoma, Stanislaus និងខោនធី Ventura ៖ ផែនការថែទាំសុខភាពដែលមានការរៀបចំទុកជាមុន ត្រូវ ផ្តល់សេវាកម្មនេះ ជូនអតិថិជនឲ្យបានក្នុងរវាង **ប្រាំពីរ (7)** ថ្ងៃ គិតពីពេលអ្នកបានស្នើសុំ ។[16]

---

14 *បទបញ្ញត្តិចុងក្រោយអំពីការថែទាំសុខភាព Medicaid ដែលមានការចាត់ចែងជាមុន (Medicaid Managed Care Final Rule)* ទំព័រ 7 "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

15 WIC §14197(d)(2)(A) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

16 WIC §14197(d)(2)(B) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

សម្រាប់អ្នករស់នៅក្នុងខោនធី Amador, Butte, El Dorado, Fresno, Kern, Kings, Lake, Madera, Merced, Monterey, Napa, Nevada, San Bernardino, San Luis Obispo, Santa Barbara, Sutter, Tulare, Yolo និងខោនធី Yuba ៖ ផែនការថែទាំសុខភាពដែលមានការរៀបចំទុកជាមុន ត្រូវ ផ្តល់សេវាកម្មនេះ ជូនអតិថិជនឲ្យបានក្នុងរវាង **ដប់បួនថ្ងៃ (14)** ថ្ងៃនៃថ្ងៃធ្វើការ គិតពីពេលអ្នកបានស្នើសុំ ។[17]

សម្រាប់អ្នករស់នៅក្នុងខោនធី Alpine, Calaveras, Colusa, Del Norte, Glenn, Humboldt, Imperial, Inyo, Lassen, Mariposa, Mendocino, Modoc, Mono, Plumas, San Benito, Shasta, Sierra, Siskiyou, Tehama, Trinity និងខោនធី Tuolumne ៖ ផែនការថែទាំសុខភាពដែលមានការរៀបចំទុកជាមុន ត្រូវ ផ្តល់សេវាកម្មនេះ ជូនអតិថិជនឲ្យបានក្នុងរវាង **ដប់បួនថ្ងៃ (14)** នៃថ្ងៃធ្វើការ គិតពីពេលអ្នកបានស្នើសុំ ។[18]

## 7. តើមានការលើកលែងចំពោះបទដ្ឋានទាំងអស់នេះដែរឬទេ?

បើផែនការថែទាំសុខភាព Medi-Cal ដែលមានការរៀបចំទុកជាមុន មិនអាចសម្រេចបានតាមបទដ្ឋានពេលវេលា និងចម្ងាយផ្លូវធ្វើដំណើរទេ ពួកគេអាចស្នើសុំបទដ្ឋានពេលវេលា និងចម្ងាយផ្លូវធ្វើដំណើរផ្សេងពីនេះ ពីនាយដ្ឋានសេវាកម្មថែទាំសុខភាព (DHCS - Department of Health Care Services) ដែលជាទីភ្នាក់ងាររដ្ឋតែមួយគត់ ដែលជាអ្នកមើលខុសត្រូវចំពោះកម្មវិធី Medi-Cal (បូករួមទាំងផែនការថែទាំសុខភាព Medi-Cal ដែលមានការរៀបចំជាមុន) ប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា ។ ផែនការថែទាំសុខភាព Medi-Cal ដែលមានការរៀបចំទុកជាមុន ត្រូវបង្ហាញឲ្យឃើញថា ខ្លួនបានប្រើគ្រប់ជម្រើសដែលមានហេតុផលសមរម្យទាំងអស់ហើយ ដើម្បីទទួលបានអ្នកផ្តល់សេវាកម្ម ។[19] ហើយអង្គភាពនេះក៏ត្រូវបង្ហាញដែរថា ហេតុអ្វីបានជាចាំបាច់ប្រើបទដ្ឋានផ្សេង ក្នុងកិច្ចការនេះ ។

---

[17] WIC §14197(d)(2)(C) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[18] WIC §14197(d)(2)(D) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[19] WIC §14197(e)(1) "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

បើ DHCS អនុម័តិលើបទដ្ឋានផ្សេង បទដ្ឋានទាំងនេះ ត្រូវបិតផ្សាយនៅតាមវិុបសៃត៍ ។[20]

ក្នុងនេះផងដែរ DHCS នឹងពិចារណាចំពោះបទដ្ឋានផ្សេងទៀតនៃពេលវេលា និងចម្ងាយផ្លូវធ្វើដំណើរ នៅពេលអ្នកផ្តល់សេវាកម្មធ្វើដំណើរទៅកាន់កន្លែងអ្នកទទួលផលរបស់ Medi-Cal និង/ឬមណ្ឌលសហគមន៍ ដើម្បីផ្តល់សេវាកម្ម ។[21]

បើអ្នកកំពុងតែទទួលបានសេវាកម្មពីផែនការថែទាំសុខភាព Medi-Cal ដែលមានការរៀបចំជាមុន តាមរយៈអ្នកផ្តល់សេវាកម្មនៅក្រៅបណ្តាញ គឺត្រូវគិតដូចគ្នា ចំពោះពេលវេលាដែលត្រូវចំណាយ ទៅកាន់អ្នកផ្តល់សេវាកម្មក្នុងបណ្តាញដែរ ។[22]

## 8. តើផែនការថែទាំសុខភាពដែលមានការរៀបចំជាមុន អាចប្រើទូរសុខភាព បច្ចេកវិជ្ជាផ្សេងទៀតសម្រាប់ទំនាក់ទំនង ឬក៏ផ្ញើការបញ្ជាទិញថ្នាំទៅឱសថស្ថានតាមប្រៃសនីយ បានដែរឬទេ?

បាន ។ DHCS អាចអនុញ្ញាតឲ្យប្រើបច្ចេកវិជ្ជាទំនាក់ទំនងដែលមានភាពសមរម្យសម្រាប់ការព្យាបាលជំងឺ ជាវិធីសាស្រ្តមួយ ក្នុងការអនុវត្តតាមគោលការណ៍បទដ្ឋានពេលវេលា និងចម្ងាយផ្លូវធ្វើដំណើរ ។[23]

---

[20] WIC §14197(e)(3) “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

[21] *បទបញ្ញត្តិចុងក្រោយអំពីការថែទាំសុខភាព Medicaid ដែលមានការចាត់ចែងជាមុន (Medicaid Managed Care Final Rule)* ទំព័រ 24 “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

[22] Id. ត្រង់ទំព័រទី 16 “ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[23] WIC §14197(e)(4) “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

## តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើផែនការថែទាំសុខភាព Medi-Cal ដែលបានរៀបចំទុកជាមុន របស់ខ្ញុំ មិនបានធ្វើតាមបទដ្ឋានទាំងអស់នេះទេនោះ?

អ្នកអាចដាក់ពាក្យប្តឹងសារទុក្ខទៅកាន់ផ្នែកការថែទាំសុខភាពដែលមានការរៀបចំទុកជាមុនរបស់ Medi-Cal[24] និង/ឬ ប្តឹងមកកាន់ផ្នែកថែទាំសុខភាព Medi-Cal ដែលមានការរៀបចំទុក នៃការិយាល័យអ្នកស៊ើបអង្កេត[25] ។

## ធនធានបន្ថែម

សូមអាន ឯកសាររបស់នាយកដ្ឋានសេវាកម្មសុខភាពកាលីហ្វ័រនីញ៉ា (CA Dept. of Health Care Services) *ស្តីអំពីបទបញ្ញត្តិចុងក្រោយនៃផែនការថែទាំសុខភាពដែលមានការចាត់ចែងជាមុន (Medicaid Managed Care Final Rule) ៖ បទដ្ឋាននៃភាពគ្រប់គ្រាន់របស់បណ្តាញ* (2017)។

យើងខ្ញុំចង់ស្តាប់យោបល់អ្នក! សូមជួយបំពេញសំណួរសម្រង់មតិខាងក្រោម ស្តីអំពីការបោះពុម្ពផ្សាយរបស់យើងខ្ញុំ

---

24 សូមអានអត្ថបទបោះពុម្ពផ្សាយរបស់យើងខ្ញុំ ស្តីអំពី ការថែទាំសុខភាព Medi-Cal ដែលមានការចាត់ចែងទុកជាមុន (Medi-Cal Managed Care) ៖ បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសារទុក្ខ ។ “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

25 សូមអានគ្រង់ចំណុច MMCD នៃការិយាល័យអ្នកស៊ើបអង្កេតសាធារណៈ (MMCD Office of the Ombudsman) “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

ហើយប្រាប់ឲ្យយើងខ្ញុំបានដឹងពីគុណភាពការងាររបស់យើងខ្ញុំ!
[ចាប់ផ្តើមបំពេញសំណួរសម្រង់មតិ]

សម្រាប់ជំនួយផ្លូវច្បាប់ សូមហៅមកលេខ 800-776-5746 ឬបំពេញ បែបបទស្នើសុំជំនួយ ។ សម្រាប់គោលបំណងផ្សេងៗទៀតទាំងអស់ សូមហៅទូរស័ព្ទមកលេខ 916-504-5800 (កាលីហ្វ័រនីញ៉ាខាងជើង) 213-213-8000 (កាលីហ្វ័រនីញ៉ាខាងត្បូង) ។

*Disability Rights California បានទទួលថវិកាឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html ។